ក

មាតិកា

I-ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

២៥-៤-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៤០៧/១៥៤ ស្តីពីការកំណត់ព្រំប្រទល់រដ្ឋបាល រវាង ខណ្ឌមានជ័យ រាជធានីភ្នំពេញ និង ស្រុកកៀនស្វាយ ខេត្តកណ្តាល ៣៣៣៩

២៥-៤-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៤០៧/១៥៥ ស្តីពីការប្រគល់ឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ត្រី** នាយអាវុធហត្ថ ជូន កញ្ញា **ខា រដ្ឋា** នាយសេនាធិការរង កងរាជអាវុធហត្ថលើផ្ទៃប្រទេស ៣៣៤១

II-រាជរដ្ឋាភិបាល

១-អនុក្រឹត្យ

២៥-៤-២០០៧ -អនុក្រឹត្យលេខ ៣៦ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ៣៣៤២

២៥-៤-២០០៧ -អនុក្រឹត្យលេខ ៣៧ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ៣៣៤៤

២៧-៤-២០០៧ -អនុក្រឹត្យលេខ ៣៨ អនក្រ.បកស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណមរកត កម្ពុជា-ឡាវ-ថៃ ៣៣៤៦

២៧-៤-២០០៧ -អនុក្រឹត្យលេខ ៣៩ អនក្រ.បកស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណ កម្ពុជា-ឡាវ-វៀតណាម ៣៣៥១

២៧-៤-២០០៧ -អនុក្រឹត្យលេខ ៤០ អនក្រ.បក ស្តីពីការប្រើប្រាស់គណនីឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ ៣៣៥៧

២៧-៤-២០០៧ -អនុក្រឹត្យលេខ ៣៤៥ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៣៣៥៩

២៧-៤-២០០៧ -អនុក្រឹត្យលេខ ៣៤៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣៣៦០

២៧-៤-២០០៧ -អនុក្រឹត្យលេខ ៣៤៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣៣៦១

២៧-៤-២០០៧ -អនុក្រឹត្យលេខ ៣៤៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣៣៦៣

២៧-៤-២០០៧ -អនុក្រឹត្យលេខ ៣៤៩ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៣៣៦៥

២៧-៤-២០០៧ -អនុក្រឹត្យលេខ ៣៥០ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៣៣៦៦

២-សេចក្តីសំរេច

២៧-៤-២០០៧ -សេចក្តីសំរេចលេខ២២ សសរ ស្តីពីការបង្កើតអនុគណៈកម្មការសំរាប់គ្រប់គ្រងថវិកា និងត្រួតពិនិត្យគុណភាពសំណង់អាគារសាកលវិទ្យាល័យបាត់ដំបង ៣៣៦៨

III-ការងារបណ្តាក្រសួង

១-ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

២៧-៣-២០០៧ -ប្រកាសលេខ ៤៦៥ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ " **សំរុង** " ស្ថិតនៅក្នុង សង្កាត់ សំរុង ខណ្ឌ ព្រៃនប់ ក្រុងព្រះសីហនុ ៣៣៧២

២៧-៣-២០០៧ -ប្រកាសលេខ ៤៦៦ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ " **សំបូរ** " ស្ថិតនៅក្នុង ឃុំ សង្កែពីរ ស្រុកឆែប ខេត្ត ព្រះវិហារ ៣៣៧៣

២៧-៣-២០០៧ -ប្រកាសលេខ ៤៦៧ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ " **អូរដារ៉ំ** " ស្ថិតនៅក្នុង ឃុំ កំពង់ល្ពៅ ស្រុក សំឡូត ខេត្ត បាត់ដំបង ៣៣៧៤

២៧-៣-២០០៧ -ប្រកាសលេខ ៤៦៨ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ " **អូរជ្រៅ** " ស្ថិតនៅក្នុង សង្កាត់ អូរជ្រៅ ខណ្ឌ ព្រៃនប់ ក្រុងព្រះសីហនុ ៣៣៧៥

២៧-៣-២០០៧ -ប្រកាសលេខ ៤៦៩ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ " **វត្តតាម៉ិម** " ស្ថិតនៅក្នុង ឃុំ រកា ស្រុក សង្កែ ខេត្ត បាត់ដំបង ៣៣៧៦

២៧-៣-២០០៧ -ប្រកាសលេខ ៤៧០ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ " **ស្ទឹងជ្រៅ** " ស្ថិតនៅក្នុង ឃុំ ដើមមាន ស្រុក តាខ្មៅ ខេត្ត កណ្តាល ៣៣៧៧

២៧-៣-២០០៧ -ប្រកាសលេខ ៤៧១ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ " **របស់មង្គល** " ស្ថិតនៅក្នុង ឃុំ របស់មង្គល ស្រុក មោងឫស្សី ខេត្ត បាត់ដំបង ៣៣៧៨

២៧-៣-២០០៧ -ប្រកាសលេខ ៤៧២ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ " **ម្រះព្រៅ** " ស្ថិតនៅក្នុង ឃុំ ជ្រៃ ស្រុក មោងឫស្សី ខេត្ត បាត់ដំបង ៣៣៧៩

២-គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

៣០-៤-២០០៧ -សេចក្តីសំរេចលេខ ២២១/០៧ គ.ជ.ប.ស.ស.រ ស្តីពីការលុបឈ្មោះបេក្ខជនជាប់ឆ្នោតតំណាងរាស្ត្រ គណបក្ស ហ្វុនស៊ិនប៉ិច ចេញពីមណ្ឌលខេត្ត ពោធិសាត់ ៣៣៨០

៣០-៤-២០០៧ -សេចក្ដីសំរេចលេខ ២២២/០៧ គ.ជ.ប.ស.ស.រ ស្ដីពីការប្រកាសទទួលស្គាល់ ឯកឧត្ដម **សាយ មង្គល** បេក្ខជនតំណាងរាស្ត្រពេញសិទ្ធិលំដាប់ទី ៣ របស់ គណបក្ស ហ៊្វុនស៊ិនប៉ិច នៅមណ្ឌល ខេត្ត ពោធិសាត់ ៣៣៨១

៣_ទីស្ដីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

១១-០១-២០០៧ -លិខិតបញ្ជាក់លេខ ០១៦៩ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហេង គីមហួត អភិវឌ្ឍន៍** ៣៣៨២

១១-០១-២០០៧ -លិខិតបញ្ជាក់លេខ ០១៧០ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ក្រចេះ ស៊ីធី ផៅវ័រ** ៣៣៨៤

១១-០១-២០០៧ -លិខិតបញ្ជាក់លេខ ០១៧១ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **មូ_គូក** ៣៣៨៦

១១-០១-២០០៧ -លិខិតបញ្ជាក់លេខ ០១៧៨ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អឹម អ ជី ត្រេឌីង** ៣៣៨៨

១១-០១-២០០៧ -លិខិតបញ្ជាក់លេខ ០១៧៩ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មនិងទទួល ស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សុខ ខេង ឌីវេឡុបមេន** ៣៣៩០

១១-០១-២០០៧ -លិខិតបញ្ជាក់លេខ ០១៨២ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហ៊ី លី អ៊ីមផត អិចផត ខូ អិលធីឌី** ៣៣៩២

១១-០១-២០០៧ -លិខិតបញ្ជាក់លេខ ០១៨៣ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហ៊្វុយជី ហ្វីម (ខេមបូឌា) គ្រុប ខូ អិលធីឌី** ៣៣៩៤

១១-០១-២០០៧ -លិខិតបញ្ជាក់លេខ ០១៨៤ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឃៀនឈេង អេគ្រី ខលឆើល ម៉ាស៊ីនណើរី ខូ អិលធីឌី** ៣៣៩៦

១២-០១-២០០៧ -លិខិតបញ្ជាក់លេខ ០១៨៥ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សិលា អង្គរ ស្ថានីយ៍វិទ្យុ អេហ្វអឹម ៩៩ មេហ្គាហឺត** ៣៣៩៨

ឃ

១២-០១-២០០៧ -លិខិតបញ្ជាក់លេខ ០១៨៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **វ៉ាយ. អឹម. ខេ. អ៊ីមផត អិចផត** ៣៤០០

១២-០១-២០០៧ -លិខិតបញ្ជាក់លេខ ០១៨៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេ ស៊ី អេស ឡូជី ស្ទីក (ខេមបូឌា)** ៣៤០២

១២-០១-២០០៧ -លិខិតបញ្ជាក់លេខ ០១៨៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ផ្កាយ ចឹហ្សូនស ទើលដ៍** ៣៤០៤

១២-០១-២០០៧ -លិខិតបញ្ជាក់លេខ ០១៨៩ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **កែន ភាន់ណាវ៉ា ខបភើរេសិន** ៣៤០៦

១២-០១-២០០៧ -លិខិតបញ្ជាក់លេខ ០១៩១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស៊ី ស៊ី អេ គ្រុប ខូ អិលធីឌី** ៣៤០៨

១២-០១-២០០៧ -លិខិតបញ្ជាក់លេខ ០១៩២ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស៊ី អិល ធី ស៊ី ត្រេឌីង** ៣៤១០

នស/រកត/០៩០៧/១៥៤

ព្រះរាជក្រឹត្យ

ស្តីពី

ការកំណត់ព្រំប្រទល់រដ្ឋបាល វាងខណ្ឌមានជ័យ រាជធានីភ្នំពេញ និង ស្រុកកៀនស្វាយ ខេត្តកណ្តាល

~~~~~~~

យើង

ព្រះករុណាព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា១.-

ត្រូវបានកំណត់ព្រំប្រទល់រដ្ឋបាលរវាងខណ្ឌមានជ័យ រាជធានីភ្នំពេញ និង ស្រុកកៀនស្វាយ ខេត្តកណ្តាល ដូចតទៅ :

ខ្សែព្រំប្រទល់គឺ ចាប់ផ្តើមចេញពីទន្លេបាសាក់រត់ទៅទិសឥសាន្ត ដោយបត់បែនតាមអ័ក្សនៃព្រែកប្រា រួចឆ្លងកាត់ស្ពានព្រែកប្រា ហើយបន្តតាមអ័ក្សនៃព្រែកប្រានេះដដែលរហូតដល់បឹងប្រា រួចរត់តាមខ្សែកណ្តាល បណ្តោយបឹងប្រានេះរហូតដល់ចំណុចដែលមាននិយាមកា (៤៩៦២០០.១២៧១៧៧៨) ទើបប្រែទិសរត់ត្រង់ឆ្ពោះទៅទិសខាងជើង រហូតដល់ចំណុច B ដែលមាននិយាមកា (៤៩៦២០០.១២៧៥៦២០) ចំណុចនេះ ស្ថិតខាងជើងផ្លូវ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
~~~~~~~

ជាតិលេខ ១ ចំងាយ ៣០ម ពីអ័ក្សផ្លូវ រួចខ្សែព្រំប្រទល់រត់បត់ទៅទិសខាងលិចស្របតាមផ្លូវជាតិលេខ ១ (រត់ខាងជើងផ្លូវជាតិលេខ ១ ដោយរក្សាចំងាយ ៣០ម ពីអ័ក្សផ្លូវ) រហូតដល់ចំណុច A ដែលមាននិយាមកា (៤៩៥៨៨០.១២៧៥៥៩០) ចំណុចនេះស្ថិតខាងជើងផ្លូវជាតិលេខ ១ ចំងាយ ៣០ម ពីអ័ក្សផ្លូវ និង ស្ថិតនៅជើងទំនប់ហែមចំរើនខាងកើត រួចប្រែទិសរត់ទៅខាងជើង តាមជើងទំនប់ហែមចំរើនផ្នែកខាងកើតរហូតដល់ចំណុចដែលមាននិយាមកា (៤៩៥៨៨០.១២៧៥៨០៥) ចំណុចនេះ ស្ថិតខាងកើតឈៀងខាងជើងនៃចុងទំនប់ហែមចំរើន ចុងបញ្ចប់ខ្សែព្រំប្រទល់រត់ចូលទៅក្នុងទន្លេមេគង្គក្រោម ដូចបានកំណត់នៅលើផែនទីដែលមានមាត្រដ្ឋាន ១:១០.០០០ UTM Zone 48 , Datum WGS84 ដែលវាស់វែងដោយឧបករណ៍ GPS Gormin Etrex Teodolite Wild T2 របស់នាយកដ្ឋានភូមិសាស្ត្រ ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០០៥ ។

មាត្រា២.-

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា៣.-

សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

នស.០៧០៤.១៦៤

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ. ថ្ងៃទី ២៤ ខែមេសា ឆ្នាំ ២០០៧

លេខៈ ៣៧៣ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ.ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ២០០៧
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
ឃុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៤០៧/១៥៦

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី
សមានគ្គមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ២០០១ ស្ដីពីការកែសំរួលតួនាទី ភារកិច្ច និងរចនា សម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយ របស់សម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : ត្រូវបានប្រគល់ឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ត្រី** នាយអាវុធហត្ថ ជូន កញ្ញា **ជា រដ្ឋា** នាយសេនាធិការរង កងរាជអាវុធហត្ថលើផ្ទៃប្រទេស

មាត្រា២ : សម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល.០៧០៤.១៦៥

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០០៧

លេខ ១៧៤ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ... ខែ មេសា ឆ្នាំ២០០៧
... ទីស្ដីការគណៈរដ្ឋមន្ត្រី រាជរដ្ឋាភិបាល

ឃុន ជិនកេន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ :...៣៦....អនក្រ.បក

រាជធានីភ្នំពេញ , ថ្ងៃទី ២៥ ខែមករា ឆ្នាំ ២០០៧

អនុក្រឹត្យ
ស្តីពីការផ្ទេរឥណទានថវិកា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១១៧, ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤, ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤, ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨, ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការ បង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣, ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ១០/នស /៩៤, ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥, ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ ត្រូវបានកែប្រែដោយច្បាប់ ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាស ឱ្យប្រើដោយព្រះរាជក្រម លេខ នស/រកម /១២០២/០២០ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២ និង ត្រូវបានកែប្រែដោយ ច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ , ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៥ /០៤០, ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៦
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក. ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក. ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០០ ស្តីពីការបំពេញបន្ថែម និង កែសំរួលនាយកដ្ឋានមួយ ចំនួន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៧១ អនក្រ.បក. ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៦

- បានឃើញប្រកាសលេខ ១៤១៧ សហវ.ថហ. ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការបែងចែកចំណាយឥណទាន ថវិកាផ្ទៃក្នុងជំពូក តាម គណនី អនុគណនី សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៧
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សំរេច

មាត្រា១ : ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទាននៅក្នុងវង្វង់ថវិការបស់ក្រសួងអប់រំ យុវជន និង កីឡា សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ចំនួន ២៩.៥៥០.១១២.០០០រៀល (ម្ភៃប្រាំពាន់ ប្រាំរយហាសិបលាន មួយរយដប់ពីរពាន់រៀលគត់) ដើម្បីបំពេញតំរូវការចំណាយចាំបាច់ ដូចមានតារាងឧបសម្ព័ន្ធភ្ជាប់ជាមួយ ។

មាត្រា២ : ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះ តាមគណនី និង អនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីបំពេញតំរូវការចំណាយជាក់ស្តែង របស់ក្រសួងអប់រំ យុវជន និង កីឡា សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ។

មាត្រា៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

បានយកសេចក្តីគោរពជូន
សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៣៧ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការផ្ទេរឥណទានថវិកា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ . ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ , ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ . ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ . ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ .ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធ ហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០ ន.ស ៩៤ . ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ . ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ . ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ .ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ និងប្រកាសលេខ ១៤០១ សហវ.ប្រក.ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការដាក់អោយអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាទូទៅរបស់រដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ . ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៧
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក . ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក . ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែមនិង កែសំរួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៧១ អនក្រ.បក . ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៧
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សម្រេច

មាត្រា១: ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកាចំនួន ៨.០០០ លានរៀល (ប្រាំបីពាន់លានរៀលគត់) ពីជំពូក ០៩ (ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ៦៤ (បន្ទុកបុគ្គលិក) ជូនក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ។

មាត្រា២: ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះ តាមគណនី និង អនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ចំណាយលើការងារកាត់រំសាយទ័ពប្រភេទ ២ ជំហាន១ ប្រចាំឆ្នាំ ២០០៧ ។

មាត្រា៣: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី២៥ ខែ មេសា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

អ៊ុក រ៉ាប៊ុន

រដ្ឋមន្ត្រីស្តីទី

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣៨ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការបង្កើតគណៈកម្មាធិការជាតិសម្រាប់សម្របសម្រួលការងារ សហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណមរកត កម្ពុជា-ឡាវ-ថៃ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/ ១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- យោងអនុក្រឹត្យលេខ ០២.អនក្រ.បក ចុះថ្ងៃទី០៥ ខែ មករា ឆ្នាំ ២០០៧ ស្តីពីការបង្កើតគណៈកម្មាធិការជាតិ សម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណមរកតកម្ពុជា-ឡាវ-ថៃ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

ស ម្រេ ច

មាត្រា ១ .-

ត្រូវបានបង្កើតគណៈកម្មាធិការជាតិ សម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណមរកត កម្ពុជា-ឡាវ- ថៃ ដែលមានសមាសភាព ដូចខាងក្រោម :

១-	ឯកឧត្តម ចម ប្រសិទ្ធ	ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម	ប្រធាន
២-	ឯកឧត្តម ឡុង វិសាលោ	រដ្ឋលេខាធិការ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ	អនុប្រធានទី១
៣-	ឯកឧត្តម ប៉ាន សូរសក្តិ	រដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម	អនុប្រធានទី២
៤-	ឯកឧត្តម ថោង ខុន	រដ្ឋលេខាធិការ ក្រសួងទេសចរណ៍	អនុប្រធាន
៥-	ឯកឧត្តម ទ្រាំ សុខា	រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ	សមាជិក
៦-	ឯកឧត្តម ត្រាំ អ៊ីវតឹក	រដ្ឋលេខាធិការ ក្រសួងសាធារណការ និងដឹកជញ្ជូន	សមាជិក
៧-	ឯកឧត្តម ចំន្ទ តុងអ៊ីវ	រដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ	សមាជិក
៨-	ឯកឧត្តម នុត ណារ៉ាង	រដ្ឋលេខាធិការ ក្រសួងដែនដីនគរូបនិយកម្ម និងសំណង់	សមាជិក
៩-	ឯកឧត្តម អ៊ិត ប្រាំង	រដ្ឋលេខាធិការ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល	សមាជិក
១០-	ឯកឧត្តម អេង ហ៊ុត	រដ្ឋលេខាធិការ ក្រសួងសុខាភិបាល	សមាជិក
១១-	ឯកឧត្តម ខុន សំនួន	រដ្ឋលេខាធិការ ក្រសួងបរិស្ថាន	សមាជិក
១២-	ឯកឧត្តម ស៊ឹម សុន	រដ្ឋលេខាធិការ ក្រសួងអភិវឌ្ឍន៍ជនបទ	សមាជិក
១៣-	ឯកឧត្តម ស្រ៊ុន តារា	អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	សមាជិក
១៤-	ឯកឧត្តម ជុំ សម្បុរ	អនុរដ្ឋលេខាធិការ ក្រសួងការពារជាតិ	សមាជិក
១៥-	ឯកឧត្តម ហ៊ុ តាំងអេង	អនុរដ្ឋលេខាធិការ ក្រសួងផែនការ	សមាជិក
១៦-	ឯកឧត្តម ហាក់ ស៊ីងលី	អនុរដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា	សមាជិក
១៧-	ឯកឧត្តម ប៉ុល ម៉េងហួរ	អនុរដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា	សមាជិក
១៨-	ឯកឧត្តម តូច សារុ	អនុរដ្ឋលេខាធិការ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ	សមាជិក
១៩-	ឯកឧត្តម ហែម សារឯម	ទីប្រឹក្សាឯកឧត្តមឧបនាយករដ្ឋមន្ត្រី ហោ ណាំហុង	សមាជិក
២០-	ឯកឧត្តម លាភ ចណ្ណរដេន	អគ្គលេខាធិការរង ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា	សមាជិក
២១-	ឯកឧត្តម សេង សក្ដា	អគ្គនាយកការងារ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ	សមាជិក
២២-	ឯកឧត្តម ឧត្តមសេនីយ៍ឯក តេង សាវង្ស	អនុប្រធានអចិន្ត្រៃយ៍នៃ អ.ជ.ប.គ.ញ	សមាជិក
២៣-	ឯកឧត្តមឧត្តមសេនីយ៍ទោ ជា ម៉ន	មេបញ្ជាការយោធភូមិភាគទី ៤	សមាជិក
២៤-	ឯកឧត្តម តឹករ៉ែត សំរេច	ជំនួយការឯកឧត្តមឧបនាយករដ្ឋមន្ត្រី សុខ អាន	សមាជិក
២៥-	លោក ឆិន សុនហាក់	ប្រធាននាយកដ្ឋានស្រាវជ្រាវអប់រំ ផ្សព្វផ្សាយធម្មទេសនា	សមាជិក
២៦-	តំណាងអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន		សមាជិក
២៧-	ឯកឧត្តមអភិបាលខេត្តសៀមរាប		សមាជិក
២៨-	ឯកឧត្តមអភិបាលខេត្តឧត្តរមានជ័យ		សមាជិក
២៩-	ឯកឧត្តមអភិបាលខេត្តព្រះវិហារ		សមាជិក
៣០-	ឯកឧត្តមអភិបាលខេត្តស្ទឹងត្រែង		សមាជិក

2

មាត្រា ២ .-

គណៈកម្មាធិការជាតិ សម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណមរកត កម្ពុជា-ឡាវ-ថៃ មានភារកិច្ច ដូចតទៅ :

- សិក្សា-រៀបចំគម្រោង និងកម្មវិធីដែលត្រូវអភិវឌ្ឍន៍ដោយឡែក និងអភិវឌ្ឍន៍រួមគ្នា ជាពិសេសលើវិស័យទេសចរណ៍ នៅក្នុងតំបន់ត្រីកោណមរកត កម្ពុជា-ឡាវ-ថៃ
- ធ្វើជាដៃគូចរចារួមថ្នាក់រដ្ឋមន្ត្រី ជាមួយភាគីឡាវ និងភាគីថៃ ក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចតំបន់ត្រីកោណមរកតកម្ពុជា-ឡាវ-ថៃ និងរួមគ្នាចរចាជាមួយភាគីផ្តល់ជំនួយទាំងអស់ ដើម្បីរកថវិកាមកអនុវត្តគម្រោងដែលបានសិក្សារួច និងដែលនឹងត្រូវសិក្សាសម្រាប់អភិវឌ្ឍន៍នៅពេលខាងមុខ
- គិតគូរអំពីតុល្យភាព នៃការប្រើប្រាស់ធនធានធម្មជាតិក្នុងតំបន់ត្រីកោណមរកត និងអត្ថប្រយោជន៍ទាំងឡាយដែលប្រជាជនកម្ពុជានឹងត្រូវទទួលបាន
- សិក្សា និងលើកយោបល់ជូនរាជរដ្ឋាភិបាល អំពីផលប៉ះពាល់នៃការអនុវត្តន៍គម្រោងនានា មកលើបរិស្ថាន វប្បធម៌ប្រពៃណី-សាសនា និងទំនៀមទំលាប់នៅក្នុងតំបន់ត្រីកោណមរកត
- រៀបចំកម្មវិធី និងគម្រោងវិនិយោគអាទិភាព លើវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងកសាងធនធានមនុស្ស
- រៀបចំផែនការសកម្មភាពសម្រាប់អភិវឌ្ឍន៍វិស័យសេដ្ឋកិច្ច អប់រំ បណ្តុះបណ្តាល សុខាភិបាល ទេសចរណ៍ ពង្រឹងសន្តិសុខសណ្តាប់ធ្នាប់សង្គមនិងបង្ក្រាបបទល្មើសឆ្លងដែននៅក្នុង និងឆ្លងកាត់តំបន់ត្រីកោណមរកត
- ទំនាក់ទំនង និងកៀរគរធនធានហិរញ្ញវត្ថុពីដៃគូអភិវឌ្ឍន៍នានា និងផ្នែកឯកជនទាំងក្នុងប្រទេស និងក្រៅប្រទេស សម្រាប់ការសិក្សាស្រាវជ្រាវ និងអនុវត្តកម្មវិធី និងគម្រោងអាទិភាពទាំងឡាយ
- ពង្រឹងការឯកភាពគ្នាក្នុងកិច្ចសហប្រតិបត្តិការក្នុងក្របខ័ណ្ឌអាស៊ាន មហាអនុតំបន់ទន្លេមេគង្គ និងកិច្ចសហប្រតិបត្តិការក្នុងអនុតំបន់ផ្សេងៗទៀត គួបផ្សំជាមួយកិច្ចសហប្រតិបត្តិការនៅតំបន់ត្រីកោណមរកត
- គណៈកម្មាធិការជាតិ សម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណមរកត កម្ពុជា-ឡាវ-ថៃ ត្រូវរាយការណ៍អំពីលទ្ធផលការងារខាងលើ ជូនរាជរដ្ឋាភិបាល ដើម្បីពិនិត្យ និងសំរេច
- បំពេញការងារដទៃទៀតតាមការណែនាំរបស់ប្រមុខរាជរដ្ឋាភិបាល

មាត្រា ៣ .-

គណៈកម្មាធិការជាតិ សម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណមរកត កម្ពុជា-ឡាវថៃ ត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ត្រារបស់ក្រសួងពាណិជ្ជកម្មលើរាល់លិខិតស្នាមផ្លូវការ និងមានថវិកាដោយឡែក សម្រាប់ការងាររបស់ខ្លួន ដែលធ្វើជាមួយនឹងគណនីរបស់ក្រសួងពាណិជ្ជកម្ម។

សមាជិកគណៈកម្មាធិការនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

ប្រធានគណៈកម្មាធិការនេះមានសិទ្ធិអញ្ជើញមន្ត្រីជាន់ខ្ពស់ និងមន្ត្រីជំនាញនៃក្រសួងពាក់ព័ន្ធឱ្យចូលរួមប្រជុំ និងធ្វើការងារ ប្រសិនជាយល់ឃើញថា មានការចាំបាច់។

មាត្រា ៤ ៈ

គណៈកម្មាធិការជាតិ សម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណមរកត កម្ពុជា-ឡាវ-ថៃ អាចបង្កើតអនុគណៈកម្មការជំនាញមួយចំនួនតាមការចាំបាច់ ។

មាត្រា ៥ ៈ

គណៈកម្មាធិការជាតិ សម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណមរកត កម្ពុជា ឡាវ-ថៃ មានលេខាធិការដ្ឋានដែលមានទីស្នាក់ការនៅទីស្តីការក្រសួងពាណិជ្ជកម្ម។ លេខាធិការដ្ឋាននេះ ត្រូវដឹកនាំដោយលេខាធិការមួយរូប និងជំនួយការមួយចំនួនតាមការចាំបាច់។ មន្ត្រីជំនួយការក្នុងលេខាធិការដ្ឋាននេះ ជាមន្ត្រីរបស់ក្រសួងពាណិជ្ជកម្ម ឬជាមន្ត្រីក្របខ័ណ្ឌពីក្រសួងស្ថាប័ននានារបស់រាជរដ្ឋាភិបាល ដែលទទួលការតែងតាំងពីប្រធានគណៈកម្មាធិការ ។

មាត្រា ៦ ៈ

លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិ សម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណមរកត កម្ពុជា-ឡាវ-ថៃ មានភារកិច្ច ដូចតទៅ :

- ជាសេនាធិការរបស់គណៈកម្មាធិការជាតិ សម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំន់ត្រីកោណមរកត កម្ពុជា-ឡាវ-ថៃ
- សម្របសម្រួលដំណើរប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិ សម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណមរកត កម្ពុជា-ឡាវ-ថៃ មានជាអាទិ៍ រៀបចំផែនការការងារ និងរៀបចំកិច្ចប្រជុំរបស់គណៈកម្មាធិការ
- សម្របសម្រួល និងទំនាក់ទំនងការងារជាមួយបណ្តាក្រសួង ស្ថាប័ន ដែលជាសមាជិកគណៈកម្មាធិការជាតិ សម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណមរកត កម្ពុជា-ឡាវ-ថៃ និងសម្របសម្រួលការងារជាមួយអនុគណៈកម្មការជំនាញ
- សម្របសម្រួលការងារជាមួយប្រទេសដៃគូអភិវឌ្ឍន៍ និងអង្គការនានា។
- បំពេញការងារដទៃ តាមការណែនាំរបស់របស់ប្រធានគណៈកម្មាធិការជាតិ សម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណមរកត កម្ពុជា-ឡាវ-ថៃ។

មាត្រា ៧ ៈ

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៨ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និង សាម៉ីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>កន្លែងទទួល</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ដូចមាត្រា ៨
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ...៣៩...អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការបង្កើតគណៈកម្មាធិការជាតិសម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណកម្ពុជា-ឡាវ-វៀតណាម

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលបានប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្រលេខ ៥៤ អនក្រ ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- យោងអនុក្រឹត្យលេខ ០១.អនក្រ.បក ចុះថ្ងៃទី០៥ ខែ មករា ឆ្នាំ ២០០៧ ស្តីពីការបង្កើតគណៈកម្មាធិការជាតិ សម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណកម្ពុជា-ឡាវ-វៀតណាម
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

ស ម្រេ ច

មាត្រា ១.-

ត្រូវបានបង្កើតគណៈកម្មាធិការជាតិ សម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណកម្ពុជា-ឡាវ- វៀតណាម ដែលមានសមាសភាព ដូចខាងក្រោម :

១-	ឯកឧត្តម ចម ប្រសិទ្ធ	ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម	ប្រធាន
២-	ឯកឧត្តម ឡុង វិសាលោ	រដ្ឋលេខាធិការ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ	អនុប្រធាន១
៣-	ឯកឧត្តម ប៉ាន់ សូរស័ក្តិ	រដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម	អនុប្រធាន២
៤-	ឯកឧត្តម ព្រុំ សុខា	រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ	សមាជិក
៥-	ឯកឧត្តម ត្រាំ អ៊ីវតឹក	រដ្ឋលេខាធិការ ក្រសួងសាធារណការ និងដឹកជញ្ជូន	សមាជិក
៦-	ឯកឧត្តម ថោង ខុន	រដ្ឋលេខាធិការ ក្រសួងទេសចរណ៍	សមាជិក
៧-	ឯកឧត្តម ច័ន្ទ តុលអ៊ីវ	រដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ	សមាជិក
៨-	ឯកឧត្តម នុត ណារ៉ង	រដ្ឋលេខាធិការ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់	សមាជិក
៩-	ឯកឧត្តម អ៊ិត ប្រាំង	រដ្ឋលេខាធិការ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល	សមាជិក
១០-	ឯកឧត្តម អេង ហ៊ុត	រដ្ឋលេខាធិការ ក្រសួងសុខាភិបាល	សមាជិក
១១-	ឯកឧត្តម សួស គង់	រដ្ឋលេខាធិការ ក្រសួងអភិវឌ្ឍន៍ជនបទ	សមាជិក
១២-	ឯកឧត្តម តាន់ ស៊ីនគូ	អនុរដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម	សមាជិក
១៣-	ឯកឧត្តម ស្រ៊ុន តារា	អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	សមាជិក
១៤-	ឯកឧត្តម ជុំ សម្បូរ	អនុរដ្ឋលេខាធិការ ក្រសួងការពារជាតិ	សមាជិក
១៥-	ឯកឧត្តម ហ៊ូ តាំងអេង	អនុរដ្ឋលេខាធិការ ក្រសួងផែនការ	សមាជិក
១៦-	លោកជំទាវ មាស ម៉ារិន	អនុរដ្ឋលេខាធិការ ក្រសួងបរិស្ថាន	សមាជិក
១៧-	ឯកឧត្តម ហាក់ ស៊ីងលី	អនុរដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា	សមាជិក
១៨-	ឯកឧត្តម ម៉ិល ម៉េងហួរ	អនុរដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា	សមាជិក
១៩-	ឯកឧត្តម អ៊ឹក សុជាតិ	អនុរដ្ឋលេខាធិការ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ	សមាជិក
២០-	ឯកឧត្តម ណី លន់	អនុរដ្ឋលេខាធិការ ក្រសួងធនធានទឹក និងឧតុនិយម	សមាជិក
២១-	ឯកឧត្តម ម៉ែម សាឯម	ទីប្រឹក្សាឯកឧត្តមឧបនាយករដ្ឋមន្ត្រី ហោ ណាំហុង	សមាជិក
២២-	ឯកឧត្តម លាភ វណ្ណៈដេន	អគ្គលេខាធិការរង ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា	សមាជិក
២៣-	ឯកឧត្តម សែម សុវណ្ណនី	អគ្គលេខាធិការរង អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន	សមាជិក
២៤-	លោកជំទាវ ជូ ប៊ុនអេង	អគ្គនាយកអភិវឌ្ឍន៍សង្គម ក្រសួងកិច្ចការនារី	សមាជិក
២៥-	ឯកឧត្តម សេង សក្ដា	អគ្គនាយកការងារ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ	សមាជិក
២៦-	ឯកឧត្តម ឧត្តមសេនីយ៍ឯក តេង សាវឌ្ឍ	អនុប្រធានអចិន្ត្រៃយ៍នៃ អ.ជ.ប.គ.ញ	សមាជិក
២៧-	ឯកឧត្តមឧត្តមសេនីយ៍ទោ ហួត ឈាង	មេបញ្ជាការយោធភូមិភាគទី ១	សមាជិក
២៨-	លោក សុខ សុតាំត្រា	អគ្គនាយករងបច្ចេកទេស ក្រសួងពាណិជ្ជកម្ម	សមាជិក
២៩-	លោក តឹកវិត សំរេច	ជំនួយការឯកឧត្តមឧបនាយករដ្ឋមន្ត្រី សុខ អាន	សមាជិក
៣០-	លោក និន សុនហាក់	ប្រធាននាយកដ្ឋានស្រាវជ្រាវអប់រំ ផ្សព្វផ្សាយធម្មទេសនា	សមាជិក

2

៣១- តំណាងអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន សមាជិក

៣២- ឯកឧត្តម អភិបាលខេត្តរតនៈគិរី សមាជិក

៣៣- ឯកឧត្តម អភិបាលខេត្តស្ទឹងត្រែង សមាជិក

៣៤- ឯកឧត្តម អភិបាលខេត្តមណ្ឌលគិរី សមាជិក

មាត្រា២ .-

គណៈកម្មាធិការជាតិ សម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណ កម្ពុជា-ឡាវ-វៀតណាម មានភារកិច្ច ដូចតទៅ :

- សិក្សា-រៀបចំគម្រោងនិងកម្មវិធីដែលត្រូវអភិវឌ្ឍន៍ដោយឡែកនិងអភិវឌ្ឍន៍រួមគ្នា នៅក្នុងតំបន់ត្រីកោណ កម្ពុជា-ឡាវ-វៀតណាម
- ធ្វើជាដៃគូចរចារួមថ្នាក់រដ្ឋមន្ត្រី ជាមួយភាគីឡាវ និងភាគីវៀតណាម ក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចតំបន់ត្រីកោណកម្ពុជា-ឡាវ-វៀតណាម និងរួមគ្នាចរចាជាមួយភាគីផ្តល់ជំនួយទាំងអស់ ដើម្បីរកថវិកាមកអនុវត្តគម្រោង
- គិតគូរអំពីតុល្យភាពនៃការប្រើប្រាស់ធនធានធម្មជាតិក្នុងតំបន់ត្រីកោណ និងអត្ថប្រយោជន៍ទាំងឡាយ ដែលប្រជាជននឹងត្រូវទទួលបាន
- សិក្សា និងលើកយោបល់ជូនរាជរដ្ឋាភិបាល អំពីផលប៉ះពាល់នៃការអនុវត្តន៍គម្រោងនានា មកលើបរិស្ថាន វប្បធម៌ ប្រពៃណី-សាសនា និងទំនៀមទំលាប់នៅក្នុងតំបន់ត្រីកោណ
- រៀបចំកម្មវិធី និងគម្រោងវិនិយោគអាទិភាព លើវិស័យហេដ្ឋារចនាសម្ព័ន្ធ និងកសាងធនធានមនុស្ស
- រៀបចំផែនការសកម្មភាព សម្រាប់អភិវឌ្ឍន៍វិស័យសេដ្ឋកិច្ច អប់រំ បណ្តុះបណ្តាល សុខាភិបាល ទេសចរណ៍ ពង្រឹងសន្តិសុខ សណ្តាប់ធ្នាប់សង្គម និងបង្ក្រាបបទល្មើសឆ្លងដែន នៅក្នុងតំបន់ត្រីកោណ
- ទំនាក់ទំនង និងកៀរគរធនធានហិរញ្ញវត្ថុពីដៃគូអភិវឌ្ឍន៍នានា និងផ្នែកឯកជនទាំងក្នុងប្រទេស និងក្រៅប្រទេស សម្រាប់ការសិក្សាស្រាវជ្រាវ និងអនុវត្តកម្មវិធី និងគម្រោងអាទិភាពទាំងឡាយ
- ពង្រឹងការឯកភាពគ្នាក្នុងកិច្ចសហប្រតិបត្តិការក្នុងក្របខ័ណ្ឌអាស៊ាន មហាអនុតំបន់ទន្លេមេគង្គ និងកិច្ចសហប្រតិបត្តិការក្នុងអនុតំបន់ផ្សេងៗទៀត
- គណៈកម្មាធិការជាតិ សម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណកម្ពុជា-ឡាវ-វៀតណាម ត្រូវរាយការណ៍អំពីលទ្ធផលការងារខាងលើ ជូនរាជរដ្ឋាភិបាល ដើម្បីពិនិត្យ និងសំរេច
- បំពេញការងារដទៃទៀត តាមការណែនាំរបស់ប្រមុខរាជរដ្ឋាភិបាល ។

មាត្រា ៣ .-

គណៈកម្មាធិការជាតិ សម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណកម្ពុជា-ឡាវ-វៀតណាម ត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ត្រារបស់ក្រសួងពាណិជ្ជកម្ម លើរាល់លិខិតស្នាមផ្លូវការ និងមានថវិកាដោយឡែកសម្រាប់ការងាររបស់ខ្លួន ដែលធ្វើជាមួយនឹងគណនីរបស់ក្រសួងពាណិជ្ជកម្ម ។

សមាជិកគណៈកម្មាធិការនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

ប្រធានគណៈកម្មាធិការនេះ មានសិទ្ធិអញ្ជើញមន្ត្រីជាន់ខ្ពស់ និងមន្ត្រីជំនាញនៃក្រសួងពាក់ព័ន្ធឱ្យចូលរួមប្រជុំ និងធ្វើការងារ ប្រសិនជាយល់ឃើញថា មានការចាំបាច់។

មាត្រា ៤ .-

គណៈកម្មាធិការជាតិ សម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណកម្ពុជា-ឡាវ-វៀតណាម មានអនុគណៈកម្មការជំនាញចំនួនបួន ដូចខាងក្រោម :

- អនុគណៈកម្មការការបរទេស និងសន្តិសុខ
- អនុគណៈកម្មការសេដ្ឋកិច្ច
- អនុគណៈកម្មការសង្គមកិច្ច និងបរិស្ថាន
- អនុគណៈកម្មការសម្របសម្រួលថ្នាក់ខេត្ត

ប្រធាន អនុប្រធាន និងសមាជិកអនុគណៈកម្មការជំនាញទាំងបួន ត្រូវតែងតាំងដោយប្រកាសរបស់ប្រធានគណៈកម្មាធិការជាតិ សម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណកម្ពុជា-ឡាវ-វៀតណាម ផ្អែកតាមការចាត់បញ្ជូនពីក្រសួង-ស្ថាប័នជំនាញនីមួយៗ ។

អនុគណៈកម្មការការបរទេស និងសន្តិសុខ ត្រូវដឹកនាំដោយប្រធានមួយរូប ដែលជាសមាជិកគណៈកម្មាធិការជាតិ សម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណកម្ពុជា-ឡាវ-វៀតណាម និងមានសមាជិកមកពី ទីស្តីការគណៈរដ្ឋមន្ត្រី (គណៈកម្មាធិការចំរុះកិច្ចការព្រំដែន) ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ អាជ្ញាធរជាតិកំចាត់គ្រឿងញៀន និង អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន។

អនុគណៈកម្មការសេដ្ឋកិច្ច ត្រូវដឹកនាំដោយប្រធានមួយរូប ដែលជាសមាជិកគណៈកម្មាធិការជាតិ សម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណកម្ពុជា-ឡាវ-វៀតណាម និងមានសមាជិកមកពី ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងផែនការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្រសួងទេសចរណ៍ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងធនធានទឹក និងឧតុនិយម ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

អនុគណៈកម្មការសង្គមកិច្ច និងបរិស្ថាន ត្រូវដឹកនាំដោយប្រធានមួយរូប ដែលជាសមាជិកគណៈកម្មាធិការជាតិ សម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណកម្ពុជា-ឡាវ-វៀតណាម និងមានសមាជិកមកពី ក្រសួងបរិស្ថាន ក្រសួងសុខាភិបាល ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្រសួងធម្មការ និងសាសនា និង ក្រសួងកិច្ចការនារី។

អនុគណៈកម្មការសម្របសម្រួលថ្នាក់ខេត្ត ត្រូវដឹកនាំដោយប្រធានមួយរូប ដែលជាសមាជិកគណៈកម្មាធិការជាតិ សម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណកម្ពុជា-ឡាវ-វៀតណាម និងមានសមាជិកមកពី ក្រសួងមហាផ្ទៃ និងតំណាងខេត្តរតនៈគិរី ខេត្តមណ្ឌលគិរី និង ខេត្តស្ទឹងត្រែង។

4

អនុគណៈកម្មការទាំងបួននេះ ធ្វើការតាមការណែនាំរបស់គណៈកម្មាធិការជាតិ សម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណកម្ពុជា-ឡាវ-វៀតណាម និងត្រូវរាយការណ៍ឱ្យទៀតទាត់តាមការកំណត់ របស់ប្រធានគណៈកម្មាធិការជាតិ សម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណកម្ពុជា-ឡាវ-វៀតណាម ។

មាត្រា ៥ ៉

គណៈកម្មាធិការជាតិ សម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណកម្ពុជា-ឡាវ-វៀតណាម មានលេខាធិការដ្ឋានដែលមានទីស្នាក់ការនៅទីស្ដីការក្រសួងពាណិជ្ជកម្ម ។ លេខាធិការដ្ឋាននេះ ត្រូវដឹកនាំដោយលេខាធិការមួយរូប និងជំនួយការមួយចំនួនតាមការចាំបាច់ ។ មន្ត្រីជំនួយការក្នុងលេខាធិការដ្ឋាននេះ ជាមន្ត្រីរបស់ក្រសួងពាណិជ្ជកម្ម ឬជាមន្ត្រីក្របខ័ណ្ឌពីក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាល ដែលទទួលការតែងតាំងពីប្រធានគណៈកម្មាធិការ ។

មាត្រា ៦ ៉

លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិ សម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណកម្ពុជា-ឡាវ-វៀតណាម មានភារកិច្ច ដូចតទៅ ៖

- ជាសេនាធិការរបស់គណៈកម្មាធិការជាតិ សម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណកម្ពុជា-ឡាវ-វៀតណាម
- សម្របសម្រួលដំណើរប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិ សម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណកម្ពុជា-ឡាវ-វៀតណាម មានជាអាទិ៍ រៀបចំផែនការការងារ និងរៀបចំកិច្ចប្រជុំរបស់គណៈកម្មាធិការ
- សម្របសម្រួល និងទំនាក់ទំនងការងារជាមួយបណ្ដាក្រសួងដែលជាសមាជិកគណៈកម្មាធិការជាតិ សម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណកម្ពុជា-ឡាវ-វៀតណាម និងអនុគណៈកម្មការ ជំនាញទាំងបួន
- សម្របសម្រួលការងារជាមួយប្រទេសដៃគូអភិវឌ្ឍន៍ និងអង្គការនានា
- បំពេញការងារដទៃ តាមការណែនាំរបស់របស់ប្រធានគណៈកម្មាធិការជាតិ សម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណ កម្ពុជា-ឡាវ-វៀតណាម ។

មាត្រា ៧ ៉

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៨ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៨
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤០ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការប្រើប្រាស់គណនី

ឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១/នស/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០២/០២១ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៣
- បានឃើញសេចក្តីជូនដំណឹងលេខ ១៣១២ សជណ.សរ ចុះថ្ងៃទី ២៩ ខែ តុលា ឆ្នាំ២០០៣ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញប្រកាសរបស់រាជរដ្ឋាភិបាល ចុះថ្ងៃទី ២០ ខែធ្នូ ឆ្នាំ ១៩៩៤ ស្តីពីឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៣៨ អនក្រ ចុះថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ១៩៩៥ ស្តីពីបែបបទនៃឯកជនភាវូបនីយកម្មសហ

គ្រោះសាធារណៈ

- បានឃើញអនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩៩៥ ស្តីពីការគ្រប់គ្រងលទ្ធកម្មសាធារណៈ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

សម្រេច

មាត្រា ១ .- អនុញ្ញាតអោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុប្រើប្រាស់គណនី ឯកជនភាវូបនីយកម្មសហគ្រោះសាធារណៈ ដែលត្រូវបានបង្កើតឡើងតាមមាត្រា ៨៣ នៃច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ លើមុខសញ្ញាចំណាយសំរាប់ការទូទាត់ប្រាក់សំណងជូនប្រជារាស្ត្រដែលទទួលរងនូវផលប៉ះពាល់ដោយសារគំរោងការស្តារឡើងវិញកំណាត់ផ្លូវជាតិលេខ ១ ភ្នំពេញ-អ្នកលឿង ក្នុងដំណាក់កាលទី ២ ចំនួន១.៣៦៥គ្រួសារ ដែលមានទឹកប្រាក់សរុបចំនួន*១.៥៨០.១៧២,២១ដុល្លារអាមេរិក* (មួយលាន ប្រាំរយប៉ែតសិបពាន់ មួយរយចិតសិបពីរដុល្លារអាមេរិក និងម្ភៃមួយសេន) ក្រោមហិរញ្ញប្បទានសហប្រតិបត្តិការរបស់រាជរដ្ឋាភិបាលជប៉ុន ។

មាត្រា ២ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន និងរដ្ឋមន្ត្រីក្រសួង-ស្ថាប័នពាក់ព័ន្ធមានភារកិច្ចអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែ មេសា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ចំលងជូន:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ២
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣៤៥ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការផ្តល់មេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **សេនា** ជូនលោកព្រឹទ្ធាចារ្យ **ឌុំ ចិល** ដែលមានស្នាដៃល្អ និងគុណបំណាច់ក្នុងការអភិវឌ្ឍវិស័យព្រះពុទ្ធសាសនា ដោយបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមជួយកសាងសាលាបាលី ខ្លោងទ្វារ សាលាបុណ្យ និង ព្រះវិហារ នៅក្រុងព្រះសីហនុ ចំណាយអស់ទឹកប្រាក់សរុបចំនួន ១០៧.២២៨ ដុល្លារអាមេរិក ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា និងអភិបាលក្រុងព្រះសីហនុ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០០៧

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣៤៦ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន០៤រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមជួយកសាងសាលាបាលី ខ្លោងទ្វារ សាលាបុណ្យ និង ព្រះវិហារ នៅក្រុងព្រះសីហនុ ដូចមានរាយនាមខាងក្រោម :-

១-លោក **នេន ម៉ាលំយ** ថវិកាចំនួន ១១.២៣៣ ដុល្លារ

២-លោកស្រី **សួន នេទី** ថវិកាចំនួន ១៣.៩៨៥ ដុល្លារ

៣-លោក **សរ សុផាន់ណា** ថវិកាចំនួន ១១.៦៦០ ដុល្លារ

៤-លោក **ជួន ស្រ៊ាង** ថវិកាចំនួន ១០.៦៥២ ដុល្លារ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា និងអភិបាលក្រុងព្រះសីហនុ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចមាត្រា ១ និង មាត្រា ២

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣៥៧ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អភិបាលខេត្តបន្ទាយមានជ័យ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេន និងជូនសប្បុរសជន នៅក្នុងនិងក្រៅប្រទេស ចំនួន ១៦ រូប ដែលមានសទ្ធាជ្រះថ្លាបានបរិច្ចាគបច្ច័យ និងថវិកា ចូលរួមជួយកសាងសមិទ្ធផលនានា លើវិស័យព្រះពុទ្ធសាសនា នៅក្នុងខេត្តបន្ទាយមានជ័យ ដូចមានរាយព្រះនាម និងនាមខាងក្រោម :-

១-ព្រះគ្រូ **ធុល សុធា** ធម្មធរគណខេត្ត និងជាព្រះអនុគណស្រុកស្វាយចេក បានចូលរួមកសាងព្រះវិហារ សាលាធម្មសភា កុដិថ្ម ស្រះទឹក នៅវត្តវេឡុវនោទ្យាន ឃុំស្វាយចេក ស្រុកស្វាយចេក បច្ច័យចំនួន ១៤.៣២០ ដុល្លារ ។

២-ព្រះគ្រូ **កើត នង់** ចៅអធិការ វត្តពោធិតាបែន ចូលរួមកសាង ព្រះវិហារ ចេតិយ៍ ស្រះទឹក ខ្លោងទ្វារ របងវត្ត ពោធិតាបែន ឃុំតាបែន ស្រុកស្វាយចេក អស់បច្ច័យចំនួន ១២.៥១២ ដុល្លារ

៣-ព្រះគ្រូ **អាន ឈួយ** ចៅអធិការ វត្តរតនៈមានជ័យ ពន្លៃជូនណូយ ចូលរួមកសាងកុដិថ្ម ព្រះវិហារ សាលាធម្មសភា ស្រះទឹក ចេតិយ៍ នៅវត្តរបស់ព្រះអង្គ ឃុំទ្រាស ស្រុកស្វាយចេក អស់បច្ច័យចំនួន ១១.៥១៨ ដុល្លារ ។

៤-ព្រះគ្រូ **សែម សុខុម** ឧទ្ទេសាចារ្យ វត្តជ័យទេពមង្គល (ហៅវត្តអូរញេរ) ចូលរួមកសាងសាលាធម្មសភា ០១ខ្នង និងសមិទ្ធផលផ្សេងៗទៀត នៅវត្តជ័យទេពមង្គល ឃុំភ្នំតូច ស្រុកមង្គលបូរី អស់បច្ច័យចំនួន ៣៤.៥០០ ដុល្លារ ។

៥-ព្រះគ្រូ **សាម គន់** ចៅអធិការវត្ត ចូលរួមជាមួយពុទ្ធបរិស័ទ ក្នុង និង ក្រៅប្រទេស កសាងព្រះវិហារ សាលាធម្មសភា និង សមិទ្ធផលមួយចំនួនទៀត នៅក្នុងវត្តបន្ទាយទូក ឃុំទ្រាស ស្រុកស្វាយចេក អស់បច្ច័យ ចំនួន ១៣. ៤០៥ ដុល្លារ ។

៦-ឧបាសិកា **ង៉ូ គិមយ៉េង** នៅសហរដ្ឋអាមេរិក បានកសាងគន្ធកុដិ០១ខ្នង ធ្វើអំពីថ្ម ២ជាន់ ជណ្តើរ និងព្រះវិហារ ក្នុងវត្តសង់ប្រាសាទរាជ្យ ឃុំភ្នំតូច ស្រុកមង្គលបូរី ចំណាយអស់ថវិកា ចំនួន ២៣.៣០០ ដុល្លារ ។

៧-ឧបាសិកា **ខាន់ ចៅ** ហៅ (**យី ស្វយ**) នៅសហរដ្ឋអាមេរិក បានកសាង កុដិថ្ម អាងទឹក បណ្ណាល័យ ប្រាង្គធំ បង្គន់អនាម័យ ជណ្តើរឡើងភ្នំ និងរបងវត្ត នៅវត្តសង់ប្រាសាទរាជ្យ ហៅ វត្ត ភ្នំតូច ឃុំ ភ្នំតូច ស្រុកមង្គលបូរី ចំណាយអស់ថវិកា ចំនួន ៥២.៤៤០ ដុល្លារ ។

៨-ឧបាសិកា **សួន ខាន់** នៅសហរដ្ឋអាមេរិក បានកសាងសាលាបុណ្យ ស្រះទឹក ព្រះវិហារ និងបណ្ណាល័យ នៅវត្តសង់ប្រាសាទរាជ្យ ឃុំភ្នំតូច ស្រុកមង្គលបូរី ចំណាយអស់ថវិកា ចំនួន ២១.៥២៥ ដុល្លារ ។

